# ជំនឿទៅលើគ្រូកំណើតរបស់អ្នកភូមិកោះកេរ

ភូមិកោះកេរ ស្ថិតនៅ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ ជាភូមិបុរាណមួយដែលស្ថិតនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទកោះកេរ។ ប្រជាជនដែលរស់នៅក្នុងតំបន់នេះភាគច្រើនជាអ្នកដែលប្រកបរបរចិញ្ចឹមជីវិតដោយអាស្រ័យផលព្រៃឈើ និងធ្វើស្រែចម្ការ។

អ្នករស់នៅក្នុងតំបន់នេះ តែងជឿទៅលើជំនឿជីវចល រួមមានអ្នកតាម្ចាស់ទឹកដី ខ្មោច ព្រាយ បិសាច។ មិនតែប៉ុណ្ណោះ អ្នកភូមិកោះកេរមានជំនឿដ៏ខ្លាំងក្លាមួយដែលតែងតែគោរពប្រតិបត្តិជាប្រចាំគឺជំនឿទៅលើ **គ្រូកំណើត** ។ អ្នករស់នៅក្នុងតំបន់នេះជឿថា រាល់មនុស្សម្នាក់ៗកើតមកតែងតែមានគ្រូកំណើតប្រចាំរៀងៗខ្លួន។ បើនិយាយឱ្យយល់ទៅគ្រូកំណើតមានន័យថាជាព្រលឹង ឬជាគ្រូដើមរបស់មនុស្សម្នាក់នោះ។ គ្រូកំណើតត្រូវបានតំណាងឱ្យវត្ថុម្យ៉ាងដែលគេហៅថា ជមគ្រូកំណើត។[១] ជមគ្រូកំណើតត្រូវបានបែងចែកទៅតាមប្រភេទកំណើតរបស់បុគ្គលនោះ។ ជមគ្រូកំណើតចែកជាពីរប្រភេទរួមមាន **ជមគុំសន្ទុំ** និង **ជមគុំសង្វារ** (រូបលេខ១-២)។ គេអាចសម្គាល់មនុស្សម្នាក់ថាជាគុំសន្ទុំបាន ដោយសារបុគ្គលម្នាក់នោះកាលពីកំណើតកើតចេញពីផ្ទៃម្តាយភ្លាមមានទងសុកនៅរុំព័ទ្ធជុំវិញប្រៀបបានជាសំណុំមួយ។ ដោយឡែកគុំសង្វារ គេអាចកំណត់សម្គាល់បានថា កាលដែលបុគ្គលនោះកើតមកភ្លាមមានទងសុករុំនៅឈៀងខ្លួន ឬក៏ក្រវាត់ជុំវិញចង្កេះ។ ចំពោះការរៀបចំជមគ្រូកំណើត ក៏ត្រូវបានបែងចែកទៅតាមប្រភេទដែរ។ អ្នកភូមិកោះកេរ គេច្រើនធ្វើ**ជមគុំសន្ទុំ**ពីផ្ទៃដូង ហើយកាត់ចេញធ្វើជាពីរថ្នាក់ ដោយថ្នាក់ទីមួយគេដោតម្ជូរនៅជុំវិញជម និងដោតលាចដាក់ចង្កាក់ និងមានដាក់ក្បាច់ស្លឹកចំនួន៣ធ្វើពីស្លឹកត្នោតដែលគេនិយមធ្វើសម្រាប់អ្នកតំបន់នេះ (រូបលេខ៣)។ ដោយឡែកថ្នាក់ខាងលើរបស់ជម គេមានដោតផ្លែត្របែកតូចៗ ទៀនរុំ ទៀនស្នែង សេកទុំលើទ្រនំធ្វើពីស្លឹកត្នោត (រូបលេខ៤-៥)។ ក្រោយពីរៀបចំផ្នែកទាំងនេះហើយគេក៏រុំក្រវាត់ចង្កេះដែលធ្វើពីស្លឹកត្នោត នៅផ្នែកចង្កេះរបស់ជម រួចរុំក្រណាត់ស នៅជុំវិញផ្នែកខាងនៃជម និងចងអំបោះសពីលើក្រណាត់នោះ។ ចំពោះ**ជមគុំសង្វារ** បើមើលទៅលើការរៀបចំមានភាពដូចគ្នាទៅនឹងជមគុំសន្ទុំដែរ ប៉ុន្តែខុសគ្នាទៅលើ ការប្រើប្រាស់វត្ថុធាតុដើមជាឈើវិញ ។

[១] អាំង ជូលាន, ២០០៦, ទំ.៤៣។

អត្ថបទដោយ៖ លោក ព្រាន់ សុភារៈ

## ***អត្ថបទ៖ ជំនឿទៅលើគ្រូកំណើតរបស់អ្នកភូមិកោះកេរ***

កាលដែលជឿទៅលើគ្រូកំណើតនេះហើយ បានជាអ្នកនៅក្នុងភូមិកោះកេរនិយមធ្វើពិធីមួយជារៀងរាល់ឆ្នាំក្នុងខែមាឃហៅថា ពិធីឡើងមេមត់ (រូបលេខ៦)។ ពិធីឡើងមេមត់នេះគេធ្វើឡើងកាលណាគេធ្វើកិច្ចប៉ូល ឬបញ្ជាន់រូប ឃើញថា ខុសមាត់ ខុសករ ពាក្យសំដីទៅលើខ្មោចញាតិសណ្ដាន ឬអ្នកតាណាមួយ ដែលធ្វើឱ្យម្នាក់នោះមានជំងឺឈឺស្កាត់ មើលពុំជា ដាក់ថ្នាំពុំត្រូវហើយក៏សន្យាធ្វើពិធីឡើងមេមត់នេះ ដើម្បីឱ្យអ្នកតា ឬខ្មោចញាតិសន្ដាននោះបានសប្បាយ និងជួយព្យាបាលខ្លួនបានជាសះស្បើយពីជំងឺ។ រាល់ពេលដែលមានមេមត់ចូលសន្ថិតក្នុងរូបស្នងគេសង្កេតឃើញថារូបស្នងនោះបានយកជមគ្រូកំណើតរៀងៗខ្លួន ដែលបានដាក់លើពានមេមត់នោះមកមើលដោយយកចិត្តទុកដាក់។ ពិធីឡើងមេមត់នៅភូមិកោះកេរនេះទៀតសោត គេតែងប្រារព្ធឡើង ដោយមានភ្លេងប្រគុំជាចាំបាច់ ហើយមេមត់បានចូលសន្ថិតតាមរយៈរូបស្នងជាបន្តបន្ទាប់ ពេលខ្លះគេលេងមួយយប់ទល់ភ្លឺក៏មានដែរ។

សរុបជារួមមកប្រជាជនដែលរស់នៅក្នុងតំបន់កោះកេរភាគច្រើន មានជំនឿជីវចលរបស់ខ្លួនពិសេសជំនឿទៅលើគ្រូកំណើត ដែលការគោរពនេះបានបន្តពីជំនាន់មួយទៅមួយជំនាន់។ មិនតែប៉ុណ្ណោះ កាលដែលមានជំនឿទៅលើគ្រូកំណើតយ៉ាងមុតមាំហើយ បានជាអ្នកក្នុងភូមិកោះកេរតែងតែប្រារព្ធធ្វើពិធីឡើងមេមត់ ឬលាងមេមត់ជារៀងរាល់ឆ្នាំ ដើម្បីជាកិច្ចមួយដែលបំពេញនូវតម្រូវការផ្សេងៗរបស់មេមត់នោះ៕

<u>ឯកសារយោង</u>


**អាំង ជូលាន**

២០០៦, "គ្រូកំណើត" *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១, ភ្នំពេញ។


*អត្ថបទដោយ៖ លោក ព្រាន់ សុភារៈ*



រូបលេខ១



រូបលេខ២



រូបលេខ៣

អត្ថបទដោយ៖ លោក ព្រាន់ សុភារៈ



រូបលេខ២៨



រូបលេខ២៩



រូបលេខ២៦